ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី
លេខ : ២០៦
ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០៦
សាលដីកា
លេខ : ៣០៧
ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ២០០៦

## នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ០៥ ខែតុលា ឆ្នាំ ២០០៦ ដោយមានសមាសភាពដូចតទៅ :

១-ឯកឧត្តម ឌិត មុន្ទី ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ
២-លោក រៀល មួន ជាចៅក្រមរបាយការណ៍
៣-លោក ឈឹម ស៊ីផល ជាចៅក្រម
៤-លោក ប៉ែន សារឿន ជាចៅក្រម
៥-លោក យស់ សូឌឿន ជាចៅក្រម

ក្រឡាបញ្ជី លោកស្រី ទី រ៉ាវី

តំណាងមហាអយ្យការ លោក ឈួន ចាន់ថា ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្ដឹងសាទុក្ខពីសាលដីកាលេខ ៦៣"ឈ" ចុះថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០០៦ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៦១៣ ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះ ឈឹម កែលាង "ជាម្ចាស់បណ្ដឹងសាទុក្ខ" ភេទប្រុស អាយុ ៥៦ឆ្នាំ ជាតិខ្មែរ របរកស៊ី អនុប្រធាននាយកដ្ឋានក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ០៩ ផ្លូវ៣៦៦ សង្កាត់ទួលស្វាយព្រៃ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

មានមេធាវីឈ្មោះ ចាន់ សុខឃាង ជាតំណាង ។

និងចុងចម្លើយឈ្មោះ សុខ ខេមរដ្ឋ "ជាម្ចាស់បណ្ដឹងសាទុក្ខ" ភេទប្រុស អាយុ ៤៦ឆ្នាំ ជាតិខ្មែរ របរកស៊ីប្រជាជន ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ៥៣ ក្រុម៨ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ គ្រួយ យ៉ាន (ស) ម្ដាយឈ្មោះ អ៊ូ សាន (ស) ។

មានមេធាវីឈ្មោះ គង់ សុភ័ក្រ ជាតំណាង ។

**កម្មវត្ថុបណ្ដឹង** : ប្ដឹងសុំគ្រប់គ្រងដី

បានឃើញបណ្ដឹងសាទុក្ខលេខ ១៤០ ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០០៦ របស់ឈ្មោះ សុខ ខេមរដ្ឋ ប្ដឹងមិនសុខចិត្តពីសាលដីកាលេខ ៦៣"ឈ" ចុះថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍លើចំណុច នៃសេចក្ដីសំរេចទាំងមូល ។

បានឃើញបណ្ដឹងសាទុក្ខលេខ ១៤៨ ចុះថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០០៥ របស់ឈ្មោះ

ឈឹម កែលាង ប្តឹងមិនសុខចិត្តពីសាលដីកាលេខ ៦៣"ឈ" ចុះថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍ លើចំណុចសុំទាមទារជំងឺចិត្តបន្ថែម នៃសេចក្តីសំរេច ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២០៦ ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០៦ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០០៥ របស់ឈ្មោះ ឈឹម កែលាង ប្តឹងសុំគ្រប់គ្រងដីទំហំ ១ហិកតា៨៥អា៦០សង់ទីអា៩៣ ស្ថិតនៅភូមិទ្រា (បច្ចុប្បន្នភូមិដំណាក់ធំ) សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ ជាកម្មសិទ្ធិ ពីឈ្មោះ សុខ ខេមរដ្ឋ ដែលរស់នៅលើដីនេះ ដោយអាងហេតុថា ដីនេះពីដើមជារបស់ឈ្មោះ សូ ងួន និងប្រពន្ធឈ្មោះ យឹម ស៊ីថា កាន់កាប់តាំងពីឆ្នាំ ១៩៨៤ ។ ក្រោយមកបានលក់ឱ្យឈ្មោះ តាំងវ៉េងជូរ និងឈ្មោះ គួច ហ៊ុយខេង នៅថ្ងៃទី ០១ ខែកក្កដា ឆ្នាំ១៩៩៣ ហើយមានប័ណ្ណសំគាល់សិទ្ធិលេខ ០០២៧៤.III₃ និងបានលក់បន្តឱ្យខ្លួន និងនាង វ៉ូច ដាង នៅថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៤ កាន់ប័ណ្ណលេខ ភព.០៦៨៦២ ។

បានឃើញដីកាសម្រេចកិច្ចការប្រញាប់លេខ ១១ប្រ."ច" ចុះថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០០៥ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារដូចតទៅ :

១-ទទួលពាក្យបណ្តឹងកិច្ចការប្រញាប់របស់ដើមចោទឈ្មោះ ឈឹម កែលាង ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០០៥ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ហាមឃាត់ចុងចម្លើយឈ្មោះ សុខ ខេមរដ្ឋ មិនឱ្យលក់ដូរ ជួល បញ្ចាំ ធ្វើអំណោយទានមរតក និងធ្វើសកម្មភាពផ្សេងៗទូវដី ដែលមានប័ណ្ណលេខ ភព.០៦៨៦២ ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០០៤ ដែលមានព្រំប្រទល់ខាងជើងទល់នឹងផ្លូវចោមចៅ ខាងត្បូងទល់នឹងដី ឯម លឹមហ៊ែល ខាងកើតទល់នឹងដីឃ្មោក ចាន់ថូ ខាងលិចទល់នឹងដី គិច លឹម ស្ថិតនៅភូមិទ្រា (បច្ចុប្បន្នភូមិដំណាក់ធំ) សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ ជាបណ្តោះអាសន្នសិន រង់ចាំអង្គសេចក្តីស្ថាពរ ។

៣-រំលងសប្រាក់ប្រដាប់ក្តីចំនួន ៤.០០០រៀល ដែលដើមចោទបានបង់ទុករួចជាស្រេច ។

៤-ដីកាសំរេចនេះមានប្រសិទ្ធភាពអនុវត្តភ្លាមៗ ទោះបីមានបណ្តឹងឧទ្ធរណ៍ក៏ដោយ ។

៥-ដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខមេធាវីតំណាងដើមចោទ កំបាំងមុខចុងចម្លើយឈ្មោះ សុខ ខេមរដ្ឋ សំរេចបើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញសាលក្រមលេខ ៧៥"ច" ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០០៥ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់លោក ឈឹម កែលាង ជាដើមចោទ ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០០៥ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិពីលោក ឈឹម កែលាង មកឱ្យលោកមេធាវី ចាន់ សុខយាងជាតំណាង ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០០៥ ទុកជាមានសុពលភាពតាមច្បាប់ ។

៣- ទទួលស្គាល់លិខិតផ្ទេរសិទ្ធិពីលោក សុខ ខេមរដ្ឋ មកឱ្យលោកមេធាវី សោម ច័ន្ទឌីណា និងលោក អ៊ុង សូទី ជាតំណាង ចុះថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ២០០៥ ទុកជាមានសុពលភាពតាមច្បាប់ ។

៤-ទទួលពាក្យបណ្តឹងតបរបស់មេធាវី សោម ច័ន្ទឌីណា និងលោក អ៊ុង សូទី ចុះថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០០៥ ទុកជាត្រឹមត្រូវតាមទំរង់ តែត្រូវបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

៥-ទទួលស្គាល់ដីដែលមានប័ណ្ណកម្មសិទ្ធិលេខ ភព.០៦៨៦២ ថាជាកម្មសិទ្ធិរបស់លោក ឈឹម កែលាង និងនាង រ៉ូច ជាង តាមប័ណ្ណខាងលើ និងតាមការបញ្ជាក់លេខ ១៨៤១៨.ន.ស.ស.សុ.ដ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០០៥ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ក្រុងភ្នំពេញ ចាប់ពីពេលនេះតទៅ ។

៦-បង្គាប់ឱ្យលោក សុខ ខេមរដ្ឋ រុះរើផ្ទះ និងសំភារៈរបស់ខ្លួនចេញពីដីនោះភ្លាម បន្ទាប់ពីសាលក្រមចូលជាស្ថាពរ ។

៧-បង្គាប់ឱ្យលោក សុខ ខេមរដ្ឋ សងជំងឺចិត្ត និងសោហ៊ុយចំណាយផ្សេងៗដល់ដើមចោទ គឺលោក ឈឹម កែលាង ចំនួន ១២.០០០ដុល្លា (មួយម៉ឺនពីរពាន់ដុល្លាអាមេរិក) សំណូមពរលើសពីនេះ បដិសេធចោល ។

-ករណីលោក សុខ ខេមរដ្ឋ គ្មានប្រាក់សង ឬពុំព្រមសង ត្រូវរឹបអូសទ្រព្យសម្បត្តិរបស់ឈ្មោះនេះលក់ឡាយឡុង ដើម្បីយកប្រាក់សងសំណងខាងលើ ។

-ករណីវង្វេស ត្រូវដាក់គុកបង្ខំលើរូបកាយ តាមច្បាប់ស្តីពី នីតិវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ។

៨-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ៧.០០០រៀល គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វ៊ីង ១.៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០រៀល សរុប ៧.០០០រៀល ដែលដើមចោទបានបង់រួចជាស្រេច ។ កាលបើសាលក្រមហួសបណ្តឹងឧទ្ធរណ៍ បង្គាប់ឱ្យចុងចម្លើយសងប្រាក់នេះឱ្យដើមចោទវិញ និងឱ្យបង់ពន្ធចំនួន ១ភាគរយ នៃប្រាក់ ១២.០០០ដុល្លា បន្ថែមតាមច្បាប់ ។

៩-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខមេធាវីតំណាងដើមចោទ និងកំបាំងមុខចុងចម្លើយ សំរេចបើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមច្បាប់កំណត់ ។

បានឃើញបណ្តឹងទាស់របស់ឈ្មោះ សុខ ខេមរដ្ឋ ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០០៥ ប្តឹងមិនសុខចិត្តលើសេចក្តីសំរេច នៃសាលក្រមទាំងមូល ។

បានឃើញសាលក្រមលេខ ៨៣"ច" ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០០៥ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់របស់ភាគីចុងចម្លើយឈ្មោះ សុខ ខេមរដ្ឋ ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០០៥ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែត្រូវបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តំកល់សាលក្រមលេខ ៧៥"ច" ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០០៥ ទុកជាមានសុពលភាពពេញទាំងមូលតាមច្បាប់តទៅ ដោយឡែកចំណុចទី៧ ត្រូវកែប្រែពីការសង ១២.០០០ដុល្លា ( មួយម៉ឺនពីរពាន់ដុល្លាអាមេរិក) មកជា ១១.០០០ដុល្លា ( មួយម៉ឺនមួយពាន់ដុល្លាអាមេរិក) វិញ រីឯចំណុចដទៃទៀតត្រូវតំកល់ទុកជាបានការពេញទាំងមូលតាមច្បាប់តទៅ ។

៣-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខមេធាវីតំណាងដើមបណ្តឹងទាស់ និងចំពោះមុខមេធាវីចុងបណ្តឹងទាស់ សំរេចបើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ សោម ច័ន្ទឌីណា និងឈ្មោះ អ៊ួង សូនី ចុះថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ២០០៥ ប្តឹងមិនសុខចិត្តលើសេចក្តីសំរេច នៃសាលក្រមទាំងមូល ។

បានឃើញបណ្តឹងឧទ្ធរណ៍របស់មេធាវី ចាន់ សុខយាង ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០០៥ ប្តឹងមិនសុខចិត្តត្រង់ចំណុចជំងឺចិត្ត នៃសាលក្រម ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍លេខ ០៦"ឈ" ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ២០០៦ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ២០០៥ របស់លោកមេធាវី សោម ច័ន្ទឌីណា និងលោកមេធាវី អ៊ួង សូនី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយផ្ទុយនឹងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងឱ្យឧទ្ធរណ៍ ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០០៥ របស់លោកមេធាវី ចាន់ សុខយាង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

៣-តំកល់សាលក្រមរដ្ឋប្បវេណីលេខ ៨៣"ច" ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០០៥ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៤-បង្គាប់ឱ្យឈ្មោះ សុខ ខេមរដ្ឋ សងជំងឺចិត្ត និងការខាតបង់ផ្សេងៗចំនួន ១០.០០០ដុល្លាអាមេរិក ( មួយម៉ឺនដុល្លាអាមេរិក) បន្ថែមទៀតឱ្យទៅដើមចោទឈ្មោះ ឈឹម កែលាង នៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។ សំណូមពរលើសពីនេះ បដិសេធចោល ។

៥-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រៀល ដែលដើមចោទបានបង់ទុករួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ៊ឹងចំនួន ២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះចំនួន ៥.០០០រៀល និងអាជ្ញាធរតុលាការចំនួន ៥.០០០រៀល ។ នៅពេលសាលដីកានេះចូលជាស្ថាពរ បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ចំនួន ១៣.០០០រៀលនេះ ទៅឱ្យដើមចោទវិញ ។

៦-សាលដីកានេះជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ១៣ ខែមករា ឆ្នាំ២០០៦ ចំពោះមុខមេធាវីតំណាងដើមចោទ កំបាំងមុខចុងចម្លើយ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៤ ខែមករា ឆ្នាំ២០០៦ ចំពោះមុខមេធាវីតំណាងដើមចោទ កំបាំងមុខចុងចម្លើយ បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់របស់ឈ្មោះ សោម ច័ន្ទឌីណា មេធាវីតំណាងឱ្យចុងចម្លើយ ចុះថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០០៦ ប្តឹងមិនសុខចិត្តលើសេចក្តីសំរេច នៃសាលដីកាទាំងមូល ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍លេខ ៦៣"ឈ" ចុះថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០០៦ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០០៦ របស់លោកមេធាវី សោម ច័ន្ទឌីណា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោល ដោយទាស់នឹងគតិច្បាប់ ។

២-តំកល់សាលដីការដ្ឋប្បវេណីកំបាំងមុខលេខ ០៦"ឈ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០០៦ ចំពោះមុខ មេធាវីតំណាងដើមចោទ. កំបាំងមុខចុងចម្លើយ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០០៦ កំបាំងមុខគូក្តី តែចាត់ទុកជាចំពោះមុខ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ១៤០ ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០០៦ របស់ឈ្មោះ សុខ ខេមរដ្ឋ ស្ថិតក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ១៤៨ ចុះថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០០៥ របស់ឈ្មោះ ឈឹម កែលាង ស្ថិតក្នុងកំណត់ច្បាប់ ។

បានឃើញ សារណារបស់ឈ្មោះ ចាន់ សុខឃាង មេធាវីតំណាងឱ្យដើមចោទ ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០០៦ ។

បានឃើញ សារណាតបរបស់ឈ្មោះ គង់ សុភ័ក្រ មេធាវីតំណាងឱ្យឈ្មោះ សុខ ខេមរដ្ឋ ចុះថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០០៦ ។

បានឃើញ សារណារបស់ឈ្មោះ ឈឹម កែលាង ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ២០០៦ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ ថា :

-បណ្តឹងសាទុក្ខរបស់ចុងចម្លើយ និងដើមចោទ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបាន ។ សាលាឧទ្ធរណ៍សំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ ។ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និងសំរេច ។

ក្រឡាបញ្ជីអានសារណារបស់លោក ឈឹម កែលាង ។

មេធាវីរបស់ចុងចម្លើយ ធ្វើសេចក្តីសន្និដ្ឋានថាៈ

-ដើមចោទថាបានទិញដីនេះពីឈ្មោះ វេង ជួរ បើទិញពីឈ្មោះនេះមែន សុំឱ្យឈ្មោះ តាំងវេង ជួរ មកប្រាប់តុលាការខ្លួនដោយផ្ទាល់ថា គាត់ពិតជាលក់ឱ្យឈ្មោះ ឈឹម កែលាង មែន ឬមិនមែន ។

តាមពិតឈ្មោះ តាំង វ៉េងជួរ បានស្លាប់តាំងពីឆ្នាំ១៩៩៧ ចំណែកលិខិតទិញ-លក់រវាងឈ្មោះ ឈឹម កែលាង និងឈ្មោះ តាំង វ៉េងជួរ ចុះឆ្នាំ២០០៤ តើស្នាមមេដៃនេះពិតជាមេដៃរបស់ឈ្មោះ តាំង វ៉េងជួរ មែនឬមិនមែន? សុំតុលាការធ្វើកោសល្យវិច័យលើស្នាមមេដៃរបស់ឈ្មោះ តាំង វ៉េងជួរ។ ចំណែកអត្តសញ្ញាណប័ណ្ណរបស់អ្នកលក់អស់សុពលភាព ។

សំណូមពរ :

-សុំផ្អាករឿងទុកមួយអន្លើ ដើម្បីស៊ើបអង្កេត ។

-សុំបង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍ និងសុំបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ ។

មេធាវីរបស់ដើមចោទ ធ្វើសេចក្ដីសន្និដ្ឋានថាៈ

-ក្រុមរបស់ចុងចម្លើយដើរនៅតែលើដីរបស់គេ បើម្ចាស់គេរករឿងឱ្យចេញ ពួកគាត់ទារលុយពីម្ចាស់ដី ទាល់តែម្ចាស់ដីឱ្យលុយពួកគាត់ បានគាត់ព្រមចេញ បើនៅយូរស្ងាត់គ្មានម្ចាស់គាត់ស៊ីដាច់តែម្ដង ។ ចុងចម្លើយថាគាត់ជាបុគ្គលិករបស់ក្រុមហ៊ុនពិភពពាណិជ្ជ ហើយក្រុមហ៊ុននេះបានឱ្យគាត់ និងបក្សពួក មកយាមដីនេះ តែគ្មានឯកសារណាបញ្ជាក់ឡើយ ។ ហើយចំពោះប្រាក់ខែរបស់ពួកគាត់ៗឆ្លើយខុសរហូត គឺនៅតុលាការឆ្លើយផ្សេង នៅក្រសួងការពារជាតិឆ្លើយផ្សេង ។ តាមពិតដីនេះជាដីរបស់ឈ្មោះសូ ងួន កាន់កាប់ពីឆ្នាំ១៩៨៤ លក់ឱ្យ តាំង វ៉េងជួរ ឆ្នាំ១៩៩៣ តាំង វ៉េងជួរ លក់ឱ្យ ឈឹម កែលាង ឆ្នាំ២០០៤ មានឯកសារទិញ-លក់ រហូតដល់មានប័ណ្ណកម្មសិទ្ធិត្រឹមត្រូវ ។ ដូច្នេះឈ្មោះ សុខ ខេមរដ្ឋ គ្មានគុណសម្បត្តិអ្វីក្នុងការតាំងខ្លួនជាគូក្ដី ដើម្បីទារប្រយោជន៍ពីម្ចាស់ដីបានឡើយ ។

ចំពោះអត្តសញ្ញាណប័ណ្ណអស់សុពលភាព គ្មានពាក់ព័ន្ធអ្វីដល់ការទិញ-លក់ដីនេះទេ ព្រោះវាគ្រាន់តែសំគាល់ឈ្មោះមនុស្សម្នាក់តែប៉ុណ្ណោះ ។ ចំណែកស្នាមមេដៃដែលខុសគ្នា គឺជួនកាលប្ដិតជួនកាលប្រពន្ធផ្ដិត ។ បើកិច្ចសន្យាទិញ-លក់នេះខុសច្បាប់ ម្ដេចក៏គ្មានអ្នកណាប្ដឹង? សុំតំកល់សាលដីការបស់សាលាឧទ្ធរណ៍ និងសុំជំងឺចិត្តបន្ថែមទៀត ។

-ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់សារណារបស់លោក ឈឹម កែលាង និងសេចក្ដីសន្និដ្ឋានរបស់មេធាវីនៃគូភាគី

-ក្រោយពីបាន ពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ១៤០ ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០០៦ របស់លោក សុខ ខេមរដ្ឋ និងបណ្ដឹងសាទុក្ខលេខ ១៤៨ ចុះថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០០៦ របស់លោក ឈឹម កែលាង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន ដោយយោងតាមមាត្រា ១៤ នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដី ។

-យល់ឃើញថា មានភស្តុតាង និងសំរាងគ្រប់គ្រាន់ថា ដីនេះដើមឡើយត្រូវបានកាន់កាប់ដោយលោក សូ ងួន និងភរិយា ហើយនៅឆ្នាំ១៩៩៣ លោក សូ ងួន បានលក់ឱ្យលោក តាំង វេងជូរ ។ ក្រោយពីបានទិញត្រឹមត្រូវតាមច្បាប់ លោក តាំង វេងជូរ បានបំពេញបែបបទធ្វើប័ណ្ណសំគាល់សិទ្ធិ និងទទួលបានប័ណ្ណលេខ ០០២៧ ង III, ចុះថ្ងៃទី ០១ ខែកក្កដា ឆ្នាំ១៩៩៣ និងបានលក់បន្តនៅឆ្នាំ២០០៤ ឱ្យលោក ឈឹម កែលាង និងភរិយា ដោយគាត់ផ្ទេរមកប័ណ្ណសំគាល់សិទ្ធិលេខ ០៦៨៦២ ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០០៤ វិញ ដូច្នេះលោក ឈឹម កែលាង និងភរិយា មានសិទ្ធិបរិបូណ៌ ជាម្ចាស់លើដីទំនាស់នេះហើយ ។

-យល់ឃើញថា នៅតុលាការក្រុងភ្នំពេញ លោក សុខ ខេមរដ្ឋ ក៏ទទួលស្គាល់ដែរថា ខ្លួននិងបក្សពួកគ្រាន់តែជាអ្នកចាំដីឱ្យក្រុមហ៊ុនសហពាណិជ្ជ ដែលមានលោក ឡាយ គឹមតុង ជាប្រធានប៉ុណ្ណោះ ដូច្នេះឈ្មោះនេះពុំមានសិទ្ធិលើដីនេះទេ ពីព្រោះពុំមានភស្តុតាងណាបញ្ជាក់ថា ដីនេះជារបស់ក្រុមហ៊ុនសហពាណិជ្ជ ហើយក៏ពុំមានការប្រគល់សិទ្ធិ ឬការប្តឹងតវ៉ាពីក្រុមហ៊ុននេះដែរ ។

-យល់ឃើញថា នាពេលសវនាការនេះ លោកមេធាវីចុងចម្លើយអះអាងថា លោក តាំង វេងជូរ បានស្លាប់នៅឆ្នាំ១៩៩៧ គឺមុនកិច្ចសន្យា ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៤ ជាការពុំត្រឹមត្រូវ ពីព្រោះលោកពុំបានជូនភស្តុតាងពីមរណភាពនេះទេ ។ តាមលិខិតលេខ ១៨៤៩ ដនសស សុជ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០០៥ លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រាជធានីភ្នំពេញ បញ្ជាក់ថា ប័ណ្ណសំគាល់អចលនវត្ថុលេខ ០៦៨៦២ ដែលកម្មសិទ្ធិករឈ្មោះ ឈឹម កែលាង និងនាង វ៉ូច ជាង បានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ ហើយតាមលិខិត ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០០៥ លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រាជធានីភ្នំពេញ ក៏បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រីដែរថា លោក ឈឹម កែលាង ពិតជាម្ចាស់ស្របច្បាប់លើប័ណ្ណកម្មសិទ្ធិខាងលើនេះ ដោយបញ្ជាក់ថា លោកបានឱ្យមន្ត្រីសុរិយោដីតាមដានដោយបានជួប និងផ្ទិតមេដៃផ្ទៀងផ្ទាត់ ឃើញថាត្រឹមត្រូវ ហើយលោក តាំង វេងជូរ នៅរស់ ដូចមានរូបថតជូនភ្ជាប់ និងការកាត់ឈ្មោះពីលោក តាំង វេងជូរ មកលោក ឈឹម កែលាង ពិតជាបានធ្វើត្រឹមត្រូវតាមច្បាប់ ។

-យល់ឃើញថា តាមលិខិត ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០០៥ របស់ឯកឧត្តមប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ បានស្នើយោបល់ជូនសម្តេចនាយករដ្ឋមន្ត្រីថា គួរស្នើតាមរយៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីឱ្យព្រះរាជអាជ្ញាតុលាការក្រុងភ្នំពេញ ធ្វើការចោទប្រកាន់លើឈ្មោះ សុខ ខេមរដ្ឋ ពីបទរំលោភលើសិទ្ធិកាន់កាប់ស្របច្បាប់លើអចលនទ្រព្យរបស់អ្នកដទៃ ។

-យល់ឃើញថា តាមលិខិត ចុះថ្ងៃទី ៦១២ក.យ.រ.ណ ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០០៥ របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌រាយការណ៍ជូនសម្តេចនាយករដ្ឋមន្ត្រីថា តាមរបាយការណ៍របស់គណៈកម្មការក្រសួងការពារជាតិ ឃើញថាឈ្មោះ ឈឹម កែលាង ពិតជាម្ចាស់ដីពិតប្រាកដ ឯឈ្មោះ សុខ ខេមរដ្ឋ ជាអ្នករំលោភបំពានលើដីរបស់គេ អាស្រ័យហេតុនេះ សូមប្រគល់ដីឱ្យ ឈឹម កែលាង ដែលមានប័ណ្ណកម្មសិទ្ធិ

ស្រាប់ ។ ក្នុងករណីដែលលោក សុខ ខេមរដ្ឋ មិនព្រមប្រគល់ និងចាកចេញពីដីនេះទេ ឱ្យលោក ឈឹម កែលាង ប្ដឹងពីបទព្រហ្មទណ្ឌ តាមមាត្រា ២៥៩ នៃច្បាប់ភូមិបាល ។

-យល់ឃើញថា តាមលិខិតលេខ ១០២២ របក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០០៦ របស់ស្នងការនគរបាលរាជធានីភ្នំពេញ ជូនឯកឧត្តមនាយឧត្តមសេនីយអគ្គនគរបាលជាតិ អំពីលទ្ធផលនៃការស្រាវជ្រាវដីទំនាស់រវាង ឈឹម កែលាង និង សុខ ខេមរដ្ឋ បានសន្និដ្ឋានថា ឈ្មោះ សុខ ខេមរដ្ឋ ពិតជាមានបំណងយកដីរបស់ ឈឹម កែលាង មែន ប៉ុន្តែបច្ចុប្បន្ននេះសំណុំរឿងខាងលើ តុលាការកំពូលកំពុងចាត់ការតាមនីតិវិធីច្បាប់ គួរបង្វិលសំណុំរឿងជូនតុលាការកំពូលចាត់ការតទៅ ហើយតាមចំណារ ចុះថ្ងៃទី ០៣ ខែតុលា ឆ្នាំ២០០៦ ឯកឧត្តមអគ្គស្នងការ ហុក ឡង់ឌី បានយល់តាមរបាយការណ៍បញ្ជូនសំណុំឯកសារទៅតុលាការកំពូល ពេលមានសាលក្រមចាត់ការអនុវត្ត ។

-យល់ឃើញថា តាមលិខិតលេខ ១០៣៥ ស.ជ.ណ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០០៥ របស់ទីស្ដីការគណៈរដ្ឋមន្ត្រីស្នើឱ្យក្រសួងយុត្តិធម៌អន្តរាគមន៍ទៅព្រះរាជអាជ្ញាតុលាការក្រុងភ្នំពេញ ធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌលើឈ្មោះ សុខ ខេមរដ្ឋ ពីបទរំលោភលើសិទ្ធិកាន់កាប់ស្របច្បាប់លើអចលនវត្ថុ និងបទក្លែងឯកសារសាធារណៈ ។

-យល់ឃើញថា លិខិតលេខ ១១១០ ស.ជ.ណ ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០០៥ របស់ទីស្ដីការគណៈរដ្ឋមន្ត្រីជូនសហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អភិបាលរាជធានីភ្នំពេញថា រាជរដ្ឋាភិបាលសំរេចប្រគល់ដីឱ្យ ឈឹម កែលាង តាមប័ណ្ណស្របច្បាប់ ។

-យល់ឃើញថា តាមលិខិតលេខ ២០៥៣ស.ជ.ណ ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០០៥ របស់សាលាក្រុងភ្នំពេញ ជំរាបលោក សុខ ខេមរដ្ឋ ឱ្យធ្វើការរុះរើសំណង់ និងចាកចេញពីដីទំនាស់ក្នុងរយៈពេល ១៥ថ្ងៃ ជាកំហិត ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

-យល់ឃើញថា តាមអនុក្រឹត្យលេខ ៨៨៦អ.ន.ក្រ.ត.ស របស់រាជរដ្ឋាភិបាល សំរេចត្រូវលុបឈ្មោះលោកវរសេនីយឯក សុខ ខេមរដ្ឋ ចេញពីក្របខ័ណ្ឌនៃកងយោធពលខេមរភូមិន្ទ ដោយមូលហេតុវិន័យរូសមិនគោរពតាមបញ្ជាថ្នាក់លើ ។

-យល់ឃើញថា ឈ្មោះ សុខ ខេមរដ្ឋ ពុំមានគុណសម្បត្តិនឹងប្ដឹងទាមទារយកដីដែលមានប័ណ្ណសំគាល់សិទ្ធិស្របច្បាប់របស់ឈ្មោះ ឈឹម កែលាង ឡើយ ។

-យល់ឃើញថា គូភាគីនៃរឿងក្ដីនេះ ពុំបានចូលរួមនាសវនាការនេះទេ ប៉ុន្តែមេធាវីនៃភាគីបានចូលរួមសវនាការនេះហើយ ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីកាឧទ្ធរណ៍លេខ ៦៣"ឃ" ចុះថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្ដីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្ដីកំបាំងមុខគូភាគី ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ ១៤០ ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០០៦ របស់លោក សុខ ខេមរដ្ឋ និងបណ្តឹងសាទុក្ខលេខ ១៤៨ ចុះថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០០៦ របស់លោក ឈឹម កែលាង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ ៦៣"ឈ" ចុះថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-រំបអូសប្រាក់ប្រដាប់ក្តីចំនួន ៣៨.០០០រៀល ដែលដើមចោទបានបង់គឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធប្តឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

-ចំណាយលើការប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល នៅសល់ ១៩.០០០រៀល ប្រគល់ឱ្យដើមចោទវិញ និងតំរូវឱ្យចុងចម្លើយសងប្រាក់ប្រដាប់ក្តីចំនួន ៩.៥០០រៀល ទៅដើមចោទវិញ ។

បង្គាប់ឱ្យចុងចម្លើយបង់ពន្ធសមាមាត្រមួយភាគរយ លើដំនឹចិត្តសរុបទាំងអស់ ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០០៦ ។